CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ០១០ សចណន

ថ្ងៃ អង្គារ ៩រោច ខែ ស្រាពណ៍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០២១

# សារាចរណែនាំ

## ស្តីពី

## ការអនុវត្តប្រកាសលេខ ០៨៤ ប្រក. ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ ស្តីពី "ការធ្វើបច្ចុប្បន្នភាពវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍"

ក្នុងគោលបំណងជួយសម្រួលដល់មូលដ្ឋានអាជីវកម្មទេសចរណ៍ ដែលកំពុងដំណើរការចូលរួមបង្ការការពារ និងរក្សាបាននូវសុវត្ថិភាព ទំនុកចិត្ត និងផ្តល់ភាពកក់ក្តៅជូនភ្ញៀវទេសចរក្នុងស្រុក ក្រសួងទេសចរណ៍បានប្រកាសឱ្យអនុវត្តនូវ **"វិធានសុវត្ថិភាពទេសចរណ៍"** ចំពោះសេវាកម្មទេសចរណ៍ចំនួន ០៦ ក្នុងនោះរួមមាន **"វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍"** ផងដែរ។

ស្របពេលដែលរាជរដ្ឋាភិបាល បាននិងកំពុងអនុវត្តយ៉ាងសកម្មនូវយុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ និងជម្រុញផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋទាំងអស់ប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវវិធានការ **"៣ការពារ ៣កុំ"** ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩នៅក្នុងសហគមន៍ ក្រសួងទេសចរណ៍បានពិនិត្យនិងធ្វើបច្ចុប្បន្នភាពលក្ខខណ្ឌនៃការអនុវត្តមួយចំនួន ឆ្លើយតបទៅនឹងគន្លងប្រក្រតីភាពថ្មីនិងស្ថានភាពនាពេលបច្ចុប្បន្ន។

ក្នុងន័យនេះ ក្រសួងទេសចរណ៍ សូមធ្វើការណែនាំដល់ម្ចាស់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់រៀបចំការអនុវត្តឱ្យបានម៉ឺងម៉ាត់នូវខ្លឹមសារប្រកាសលេខ០៨៤ ប្រក. ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ស្តីពី **"ការធ្វើបច្ចុប្បន្នភាពវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍"** ដូចខាងក្រោម៖

១.១. អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ទាំងអស់ ត្រូវដាក់ពាក្យស្នើសុំលិខិតបញ្ជាក់ និងឡាបិលអំពីការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ តាមរយៈមន្ទីរទេសចរណ៍រាជធានី ខេត្ត និងត្រូវខិតខំរៀបចំកែសម្រួលបរិវេណ និងបែបបទការងាររបស់ខ្លួនឱ្យបានសមស្របទៅនឹងការកំណត់ជាលក្ខណៈវិនិច្ឆ័យនីមួយៗ នៃវិធានសុវត្ថិភាពទេសចរណ៍។

១.២. ត្រូវរៀបចំផែនការកែតម្រូវសម្បទាអាជីវកម្មរបស់ខ្លួនឱ្យស្របនឹងលក្ខខណ្ឌតម្រូវ និងចំនុចណែនាំទាំងឡាយដូចមានកំណត់ក្នុងខ្លឹមសារប្រកាសលេខ ០៨៤ ប្រក. ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០២១ស្តីពី"ការធ្វើបច្ចុប្បន្នភាពវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសរចណ៍"។ រាល់ម្ចាស់អាជីវកម្មត្រូវចាត់ទុកលក្ខខណ្ឌទាំងនោះជាគោលការណ៍ណែនាំចម្បងសម្រាប់ការអនុវត្តក្នុងដំណាក់កាលនេះ និងត្រូវអនុវត្តឱ្យបានហ្មត់ចត់ និងប្រកបដោយស្មារតីទទួលខុសត្រូវ។

១.៣. ត្រូវមានស្មារតីភ្ញាក់រលឹក គិតគូរអំពីបញ្ហាសុវត្ថិភាពភ្ញៀវ សុវត្ថិភាពបុគ្គលិក និងសុវត្ថិភាពសង្គម-ជាតិជាអាទិភាពចំពោះមុខ។ រាល់ម្ចាស់អាជីវកម្មត្រូវហ៊ានលះបង់ធនធាន កម្លាំង និងពេលវេលា ដើម្បីត្រៀមលក្ខណៈសម្បត្តិឱ្យបានសមស្រប នឹងលក្ខខណ្ឌតម្រូវមុននឹងសម្រេចធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។

១.៤. ត្រូវរៀបចំការបណ្តុះបណ្តាលបុគ្គលិករបស់ខ្លួនឱ្យបានជាប់ជាប្រចាំអំពីវិធានការ "៣ការពារ ៣កុំ" អំពីវិធានការផ្សេងទៀតសំដៅបង្ការនិងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ អំពីរបៀបកំណត់អត្តសញ្ញាណបុគ្គលសង្ស័យមានផ្ទុកមេរោគកូវីដ១៩និងអំពីរបៀបរាយការណ៍អំពីករណីសង្ស័យជាដើម។

១.៥. ត្រូវចូលរួមផ្សព្វផ្សាយរាល់វិធានការនានាដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដែលសំដៅបង្ការនិងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩។

១.៦. ត្រូវបង្កលក្ខណៈងាយស្រួល និងជម្រុញឱ្យបុគ្គលិករបស់ខ្លួនទាំងអស់ រួមទាំងក្រុមគ្រួសាររបស់ពួកគាត់ទៅទទួលយកការចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ ឱ្យបានគ្រប់គ្នា និងឱ្យបានគ្រប់ចំនួនដូសតាមការកំណត់។

១.៧. ត្រូវអនុវត្ត និងប្រើប្រាស់ឱ្យបានត្រឹមត្រូវនូវគ្រប់ប្រព័ន្ធបច្ចេកវិទ្យាដែលបានដាក់ឱ្យអនុវត្តកន្លងមកដោយរាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធ រួមមាន៖ ការស្កេន QR Code ទប់ស្កាត់កូវីដ១៩ និងចុះទិន្នន័យបុគ្គលិកចាក់វ៉ាក់សាំងតាមប្រព័ន្ធ Telegram BOT ជាដើម។

ក្រសួងទេសចរណ៍ សូមណែនាំអំពីការអនុវត្តខ្លឹមសារប្រកាសខាងលើ ជាដំណាក់កាល ដូចខាងក្រោម៖

**ដំណាក់កាលទី១** ៖ អាជីវកម្មសណ្ឋាគារចត្តាឡីស័ក្តទាំងអស់ត្រូវចូលរួមអនុវត្តខ្លឹមសារប្រកាសខាងលើ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ដំណាក់កាលទី២** ៖ អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ទាំងអស់ ដែលមានទីតាំងស្ថិតនៅក្នុងគោលដៅ "ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព" ត្រូវអនុវត្តខ្លឹមសារប្រកាសខាងលើនេះបន្ទាប់ពីថ្ងៃចាប់បើកដំណើរការទេសចរណ៍អន្តរជាតិត្រលប់មកវិញ។

**ដំណាក់កាលទី៣** ៖ អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ទាំងអស់ដែលស្ថិតនៅក្រៅគោលដៅ "ការធ្វើដំណើរ និងទេសចរណ៍សុវត្ថិភាព" ត្រូវអនុវត្តខ្លឹមសារប្រកាសខាងលើជាជំហានដូចខាងក្រោម៖

- **ជំហានទី១** ៖ អាជីវកម្មសណ្ឋាគារចំណាត់ថ្នាក់ ផ្កាយ៤ និងផ្កាយ៥ ត្រូវអនុវត្តខ្លឹមសារប្រកាសខាងលើចាប់ពីថ្ងៃចាប់បើកដំណើរការទេសចរណ៍អន្តរជាតិត្រលប់មកវិញ។
- **ជំហានទី២** ៖ ក្នុងរយៈពេលសមស្របក្រោយប្រកាសបើកដំណើរការទេសចរណ៍អន្តរជាតិត្រលប់មកវិញ អាជីវកម្មសណ្ឋាគារគ្រប់កម្រិតទាំងអស់ត្រូវអនុវត្តខ្លឹមសារប្រកាសខាងលើជាកាតព្វកិច្ច។

ទទួលបានសេចក្តីណែនាំនេះ សូម រដ្ឋបាលរាជធានី ខេត្ត និងម្ចាស់អាជីវកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវអនុវត្តសារាចរណែនាំនេះប្រកបដោយស្មារតីទទួលខុសត្រូវ។

រដ្ឋមន្ត្រី

ថោង ខុន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

  *"ដើម្បីជូនជ្រាប"*
- សាលារាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត

  *"ដើម្បីអនុវត្ត"*
- សហព័ន្ធទេសចរណ៍កម្ពុជា
- សមាគមសណ្ឋាគារកម្ពុជា

  *"ដើម្បីសហការ"*
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ